**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ៥៩០ គ.ជ.ប.ស.ស.រ

# សេចក្ដីសម្រេច

## ស្ដីពី

## ការដាក់ឱ្យប្រើប្រាស់បទបញ្ជា និងនីតិវិធី សម្រាប់ការអនុវត្តមាត្រា ១៣៨ស្ទួន នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០៤៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការប្រកាសឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងការអនុម័តរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ លើបទបញ្ជា និងនីតិវិធីសម្រាប់ការអនុវត្តមាត្រា ១៣៨ស្ទួន នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវបទបញ្ជា និងនីតិវិធីសម្រាប់ការអនុវត្តមាត្រា ១៣៨ស្ទួន នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមាន ៧(ប្រាំពីរ) ប្រការ។

**ប្រការ ២.-**

បទបញ្ជា និងនីតិវិធីនេះ ត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក

# បទបញ្ជា និងនីតិវិធី
# សម្រាប់ការអនុវត្តមាត្រា ១៣៨ស្ទួន នៃច្បាប់ស្តីពីវិសោធនកម្ម
# ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**ប្រការ ១.-**

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងតាមរយៈក្របខណ្ឌអំណាចដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិអំណាច និងភារកិច្ចក្នុងការរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់អនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីរៀបចំបែបបទធ្វើការបែងចែកអាសនៈដែលនៅទំនេរក្នុងករណីដូចមានចែងក្នុងប្រការ ២ ខាងក្រោម ។

**ប្រការ ២.-**

ក្នុងនីតិកាលនៃរដ្ឋសភា ប្រសិនបើមានគណបក្សនយោបាយណាមួយប្រកាសបោះបង់ចោលអាសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងតំណាងរាស្ត្រទាំងអស់នៃគណបក្សនយោបាយនោះលែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។

២.១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈ ដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានលិខិតជូនដំណឹងជាផ្លូវការពីរដ្ឋសភា ឬ/និងក្រសួងមហាផ្ទៃ ទៅឱ្យគណបក្សនយោបាយនានា ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងរាជធានី ខេត្ត ជាមួយដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភា ដែលដឹកនាំរាជរដ្ឋាភិបាល ។

២.២ គ.ជ.ប ត្រូវបង្កើតក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យសំឡេងឆ្នោតបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដើម្បីពិនិត្យសម្រេច ។

២.៣ នៅមុនការបែងចែកអាសនៈ ដែលនៅទំនេរតាមករណីដូចខាងលើ គ.ជ.ប ត្រូវធ្វើលិខិតជាផ្លូវការទៅគណបក្សនយោបាយនានា ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងរាជធានី ខេត្តជាមួយលើកលែងតែគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពី

បញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភា ដែលដឹកនាំរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួល និងកំណត់បញ្ហាមួយចំនួនដូចខាងក្រោម។

ទី១- ការពិនិត្យបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួន ដែលត្រូវបានយល់ព្រមដោយ គ.ជ.ប ឱ្យចុះបញ្ជីក្នុងនីតិកាលនៃរដ្ឋសភា ដោយត្រូវលុបចេញឈ្មោះបេក្ខជនដែល៖

- ទទួលមរណភាព ឬ
- បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័ន មានសមត្ថកិច្ច ឬ
- លាឈប់ជាលាយលក្ខណ៍អក្សរ ឬ
- ត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ឬ
- បាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

ទី២- ករណីគណបក្សនយោបាយណាមួយពុំបានឆ្លើយតបតាមលិខិតផ្លូវការរបស់ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន)ថ្ងៃ តាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប នោះចាត់ទុកថា គណបក្សនយោបាយនោះ បានយល់ព្រមរក្សាទុកជាបានការនូវបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួន ដែលត្រូវបានយល់ព្រមឱ្យចុះបញ្ជីក្នុងនីតិកាលរដ្ឋសភា។

**ប្រការ ៣.-**

ការបែងចែកអាសនៈ ដែលនៅទំនេរត្រូវអនុវត្តតាមករណី និងជំហានទាំងឡាយដូចខាងក្រោម។

៣.១ ករណីដូចមានចែងក្នុងចំណុច ២.១ នៃប្រការ ២ ខាងលើ ការបែងចែកអាសនៈ ដែលនៅទំនេរត្រូវអនុវត្តតាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទី១ : កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួល ១ (មួយ) អាសនៈ**

៣.១.១ ការកំណត់ចំនួនកូតាត្រូវអនុវត្តតាមរូបមន្តខាងក្រោម ៖

$$ក'_{គ} = \frac{ស់'_{ស}}{អ'_{ប}}$$

ក្នុងនោះ ៖

- ក'គ : តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក។
- ស'ស : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ

ស្របតាម ច្បាប់ស្តីពីគណបក្សនយោបាយ និងដកចេញនូវសន្លឹកឆ្នោតបានការដែលបាន បោះឱ្យគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភា ដែលដឹកនាំរាជរដ្ឋាភិបាល។

- $អ'_{ប}$ : តាងឱ្យអាសនៈដែលនៅទំនេរ ក្នុងរាជធានី ខេត្ត។

<u>ឧទាហរណ៍</u>

នៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** មានអាសនៈចំនួន ៦ មានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចំនួន៧ ដែលក្នុងនោះ ៖

- គណបក្សនយោបាយ ក មាន $ស_{ប}ក$ ១២០.៦២២ ទទួលបាន ៣ អាសនៈ
- គណបក្សនយោបាយ ខ មាន $ស_{ប}ខ$ ១១១.៩៦៣ ទទួលបាន ៣ អាសនៈ
- គណបក្សនយោបាយ គ មាន $ស_{ប}គ$ ២.១៥៣ ទទួលបាន 0 អាសនៈ
- គណបក្សនយោបាយ ឃ មាន $ស_{ប}ឃ$ ១៤.៥៣២ ទទួលបាន 0 អាសនៈ
- គណបក្សនយោបាយ ង មាន $ស_{ប}ង$ ២.១១៦ ទទួលបាន 0 អាសនៈ
- គណបក្សនយោបាយ ច មាន $ស_{ប}ច$ ៣៧.២៥០ ទទួលបាន 0 អាសនៈ
- គណបក្សនយោបាយ ឆ មាន $ស_{ប}ឆ$ ៧.២៦៦ ទទួលបាន 0 អាសនៈ

ករណីគណបក្ស ខ បានបោះបង់ចោលអាសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ អនុវត្តតាមចំណុច ២.១ អាសនៈដែលទំនេរចំនួន ៣(បី)នេះ ត្រូវបែងចែកឱ្យទៅបញ្ជីបេក្ខជននៃគណបក្ស **គ ឃ ង ច** និង **ឆ** ដែលបានចូលរួមក្នុងការបោះឆ្នោតនៅខេត្តនោះ ។

ដូចនេះអនុវត្តតាមរូបមន្តក្នុងចំណុច ៣.១.១ ខាងលើ យើងកំណត់កូតាដែលតម្រូវឱ្យទទួលបានអាសនៈដែលទំនេរ ១(មួយ) អាសនៈ ៖

$ស'_{ប}$ = ( ១២០.៦២២+១១១.៩៦៣+២.១៥៣+១៤.៥៣២+២.១១៦+៣៧.២៥០+៧.២៦៦) - (១២០.៦២២ + ១១១.៩៦៣) = ៦៣.៣១៧

$អ'_{ប}$ = ៣

$$ក'_{គ} = \frac{ស'_{ប}}{អ'_{ប}} = \frac{៦៣.៣១៧}{៣} = \underline{\textbf{២១.១០៥}}$$

កូតាស្មើនឹង ២១.១០៥ ។

**ជំហានទី២ : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួល**

៣.១.២ ការកំណត់ចំនួនអាសនៈជាបឋមដែលគណបក្សនយោបាយនីមួយៗបានទទួល ត្រូវអនុវត្តតាមរូបមន្តខាងក្រោម ៖

$$\text{អ'}_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក'}_{\text{គ}}}$$

ក្នុងនោះ៖

- $\text{អ'}_{\text{ទ}}$ : តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត បានទទួល មុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី៣។
- $\text{ស}_{\text{ប}}$ : តាងឱ្យសន្លឹកឆ្នោតបានការសរុបបោះឱ្យគណបក្សនយោបាយមួយក្នុងរាជធានីខេត្ត ។
- $\text{ក'}_{\text{គ}}$ : តាងឱ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទី១ ។

<u>ឧទាហរណ៍</u>

ការបែងចែកអាសនៈដែលទំនេរលើកទី ១ នៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** ដដែល ។ អនុវត្តតាមការបែងចែកអាសនៈដែលទំនេរលើកទី ១ តាមរូបមន្តក្នុងជំហានទី ២ ចំណុច ៣.១.២ យើងបាន ៖

| | | | | |
|---|---|---|---|---|
| គណបក្សនយោបាយ | គ | អ'ទគ | = ២.១៥៣ / ២១.១០៥ | = ០,១០ |
| គណបក្សនយោបាយ | **ឃ** | អ'ទឃ | = ១៤.៥៣២ / ២១.១០៥ | = ០,៦៨ |
| គណបក្សនយោបាយ | ង | អ'ទង | = ២.១១៦ / ២១.១០៥ | = ០,១០ |
| គណបក្សនយោបាយ | ច | អ'ទច | = ៣៧.២៥០ / ២១.១០៥ | = ១,៧៦ |
| គណបក្សនយោបាយ | ឆ | អ'ទឆ | = ៧.២៦៦ / ២១.១០៥ | = ០,៣៤ |

តាមលទ្ធផលនៃការគណនាខាងលើ គណបក្សនយោបាយ **ច** ទទួលបាន ១(មួយ)អាសនៈ រីឯគណបក្ស **គ ឃ ង** និង **ឆ** ពុំទទួលបានអាសនៈដែលទំនេរនេះទេ ។ បន្ទាប់ពីការបែងចែកអាសនៈដែលទំនេរលើកទី ១ តាមរូបមន្តជំហានទី ២ ឃើញថាមាននៅសល់អាសនៈចំនួន ២(ពីរ) ដែលត្រូវបែងចែកទៀត ។ ដូចនេះអាសនៈទាំងនោះត្រូវយកមកបែងចែកបន្តទៀតដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តដូចខាងក្រោម ៖

### ជំហានទី ៣ : ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈដែលទំនេរ (លើកទី ២)

៣.១.៣ ដើម្បីកំណត់មធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ ត្រូវធ្វើការគណនាដោយយកចំនួនសន្លឹកឆ្នោតបានការសុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួល ចែកនឹងចំនួនអាសនៈ ដែលគណបក្សនយោបាយមួយបានទទួលបន្ទាប់ពីការបែងចែកអាសនៈ ដែលទំនេរលើកទី ១ បូកនឹងលេខនិមិត្តចំនួន ១ តាមរូបមន្តខាងក្រោម ៖

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ទ} + ១}$$

ក្នុងនោះ

- $ម'_{ធ}$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត ។
- $ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។
- $អ'_{ទ}$ : តាងឱ្យចំនួនអាសនៈ ដែលបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។
- ១ : ជាលេខនិមិត្ត ។

៣.១.៤ ការរកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវគណនាឱ្យដល់ចំនួន ២(ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់គណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ ។

៣.១.៥ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗរួចមក ត្រូវធ្វើការប្រៀបធៀបគ្នា ។ គណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតដល់ចំនួន ២ខ្ទង់ក្រោយក្បៀស) នឹងត្រូវទទួលបានអាសនៈ ១(មួយ) ។

<u>ឧទាហរណ៍</u>

ការបែងចែកអាសនៈដែលទំនេរ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតនៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** ដដែល ។

បន្ទាប់ពីការបែងចែកអាសនៈដែលទំនេរ (លើកទី ១) តាមរូបមន្តជំហានទី ២ រួចមកឃើញថា មាននៅសល់អាសនៈចំនួន ២(ពីរ) ត្រូវបែងចែកបន្ត ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ យើងបាន ៖

គណបក្សនយោបាយ គ $ម'_{ធគ} = \frac{២.១៥៣}{0+១} = ២.១៥៣.00$

គណបក្សនយោបាយ ឃ ម'ធឃ = ១៩.៥៣១ / ០+១ = ១៩.៥៣១,០០

គណបក្សនយោបាយ ង ម'ធង = ២.១១៦ / ០+១ = ២.១១៦,០០

គណបក្សនយោបាយ ច ម'ធច = ៣៧.២៥០ / ១+១ = **១៨.៦២៥,០០**

គណបក្សនយោបាយ ឆ ម'ធឆ = ៧.២៦៦ / ០+១ = ៧.២៦៦,០០

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងប្រាំខាងលើ គណបក្ស ច មានមធ្យមភាគធំជាងគេគឺ <u>១៨.៦២៦៥,០០</u> ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស ច ត្រូវទទួលបានអាសនៈដែលទំនេរចំនួន ១(មួយ) ក្នុងការបែងចែកលើកនេះ ។

៣.១.៦ ប្រសិនបើមាននៅសល់អាសនៈទៀត អាសនៈដែលនៅសល់នោះ ត្រូវបន្តបែងចែកម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ ដដែល ដោយត្រូវបង្កើនតម្លៃ អទ ចំនួន ១(មួយ) ចំពោះគណបក្សនយោបាយណាដែលទើបទទួលបានអាសនៈបន្ថែមចំនួន ១(មួយ) ។

<u>**ឧទាហរណ៍**</u>

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ យើងបាន ៖

| គណបក្សនយោបាយ | សប | អទ លើកទី១ | មធ១ | | អទ លើកទី២ | មធ២ | | អទ លើកទី៣ |
|---|---|---|---|---|---|---|---|---|
| គ | ២.១៥៣ | ០ | ២.១៥៣ / ០+១ | = ២.១៥៣ | ០ | ២.១៥៣ / ០+១ | = ២.១៥៣ | ០ |
| ឃ | ១៩.៥៣១ | ០ | ១៩.៥៣១ / ០+១ | = ១៩.៥៣១ | ០ | ១៩.៥៣១ / ០+១ | **= ១៩.៥៣១** | ១ |
| ង | ២.១១៦ | ០ | ២.១១៦ / ០+១ | = ២.១១៦ | ០ | ២.១១៦ / ០+១ | = ២.១១៦ | ០ |
| ច | ៣៧.២៥០ | ១ | ៣៧.២៥០ / ១+១ | **= ១៨.៦២៥** | ១ | ៣៧.២៥០ / ២+១ | = ១២.៤១៦,៦៦ | ០ |
| ឆ | ៧.២៦៦ | ០ | ៧.២៦៦ / ០+១ | = ៧.២៦៦ | ០ | ៧.២៦៦ / ០+១ | = ៧.២៦៦ | ០ |

តាមឧទាហរណ៍ក្នុងតារាងខាងលើ ៖

- ស$_{៥}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។
- អ'$_{៩}$ : (លើកទី១) តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយទទួលបានក្នុងការបែងចែកក្នុងជំហានទី២ ដែលបង្ហាញថា គណបក្ស ច បានទទួល ១(មួយ)អាសនៈ។
- ម'$_{៨}$១ : តាងឱ្យលទ្ធផលនៃការគណនាមធ្យមភាគលើកទី ១ (ការបែងចែកអាសនៈលើកទី២) សម្រាប់គណបក្សនយោបាយនីមួយៗ ដែលលទ្ធផលបង្ហាញថា គណបក្ស ច មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ'$_{៩}$ : (លើកទី២) គណបក្ស ច ទទួលបាន ១(មួយ)អាសនៈ ។
- ម'$_{៨}$២ : លទ្ធផលបង្ហាញថា គណបក្ស ឃ មធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ'$_{៩}$ : (លើកទី៣) គណបក្ស ឃ ទទួលបាន ១(មួយ)អាសនៈ ។

ក្នុងការបែងចែកអាសនៈដែលទំនេរ ក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** គឺគណបក្ស ឃ បានទទួល ១ អាសនៈ និង គណបក្ស ច បានទទួល ២ អាសនៈ។

បន្ទាប់ពីការបែងចែកអាសនៈដែលទំនេរ នៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** យើងបាន ៖

| | | | |
|---|---|---|---|
| គណបក្សនយោបាយ | ក | បានទទួលអាសនៈ | ៣ |
| គណបក្សនយោបាយ | គ | បានទទួលអាសនៈ | ០ |
| គណបក្សនយោបាយ | ឃ | បានទទួលអាសនៈ | ១ |
| គណបក្សនយោបាយ | ង | បានទទួលអាសនៈ | ០ |
| គណបក្សនយោបាយ | ច | បានទទួលអាសនៈ | ២ |
| គណបក្សនយោបាយ | ឆ | បានទទួលអាសនៈ | ០ |

៣.២ ក្នុងករណីគណនាតាមរូបមន្តដូចចែងក្នុងចំណុច ៣.១.៣ ខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នាដែលមិនអាចកំណត់បែងចែកអាសនៈ ដែលនៅសល់ទៅឱ្យគណបក្សនយោបាយណាមួយបាន អាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**ប្រការ ៤.-**

ក្នុងករណីគណនាតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដូចខាងលើ មានគណបក្សពីរ ឬច្រើនបានមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងមានចំនួនសន្លឹកឆ្នោតបានការស្មើគ្នា ដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឱ្យគណបក្សនយោបាយណាមួយបាន នោះអាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គ.ជ.ប ត្រូវប្រគល់ភារកិច្ចឱ្យអគ្គលេខាធិការដ្ឋាន គ.ជ.ប ចាត់ចែងរៀបចំការចាប់ឆ្នោត ។

៤.១ ការចាប់ឆ្នោត ដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយឈ្នះឆ្នោតត្រូវធ្វើជាសាធារណៈ ។

៤.២ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើនៅទីស្តីការ គ.ជ.ប ក្រោយពេលបញ្ចប់ការបែងចែកអាសនៈតាមមណ្ឌលបោះឆ្នោតនៃរាជធានី ខេត្តពាក់ព័ន្ធ ។

៤.២.១ គ.ជ.ប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីនៃការចាប់ឆ្នោត ហើយត្រូវអញ្ជើញ ៖

- យាងសម្តេចព្រះសង្ឃរាជ ឬព្រះរាជតំណាង ជាអធិបតីក្នុងពិធីចាប់ឆ្នោត
- ភ្នាក់ងារ ឬតំណាងផ្លូវការនៃគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។
- ភ្នាក់ងារ ឬតំណាងផ្លូវការនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។
- អ្នកសង្កេតការណ៍ ដើម្បីចូលរួមក្នុងពិធីចាប់ឆ្នោតនេះ ។

៤.២.២ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមជំហានដូចខាងក្រោម ៖

- ត្រូវសរសេរ ឬបោះពុម្ពនៅលើក្រដាសដែល មានប្រភេទ ទំហំ និងពណ៌ ដូចគ្នានូវឈ្មោះនៃគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផល គណនាស្មើគ្នា ។ ក្រដាសឆ្នោតមួយសន្លឹកត្រូវសរសេរ ឬបោះពុម្ពឈ្មោះ តែមួយគណបក្សនយោបាយប៉ុណ្ណោះ ។ តួអក្សរជាឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា ។ ក្រដាសសន្លឹកឆ្នោតដែលសរសេរ ឬបោះពុម្ពឈ្មោះរបស់ គណបក្សនយោបាយ រួចហើយត្រូវបត់ជាផ្នត់ដូចគ្នា ដាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទ ពណ៌ និងទំហំដូចគ្នា រួច បិទភ្ជិត ដោយមូរនិងចងកៅស៊ូកងពណ៌ដូចគ្នា ។

- ត្រូវបង្ហាញហិបឆ្នោតទទេជាសាធារណៈ មុននឹងដាក់សំបុត្រសន្លឹកឆ្នោតចូលទៅក្នុងហិបនោះ និងបិទគម្រប ។
- ត្រូវក្រឡុកហិបឆ្នោត រួចលើកហិបឆ្នោតនោះទៅដាក់លើតុខ្ពស់ ។
- ត្រូវយាងសម្តេចព្រះសង្ឃរាជ ឬព្រះរាជតំណាង ដែលត្រូវបានគណបក្សនយោបាយពាក់ព័ន្ធទុកចិត្ត និងយល់ព្រម ឱ្យចាប់យកសំបុត្រសន្លឹកឆ្នោតមួយពីក្នុងហិបនោះ រួចជូនទៅមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ។
- មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ត្រូវបើកស្រោមសំបុត្រនោះ ជាសាធារណៈ រួចអានប្រកាសឈ្មោះគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈ និងលើកបង្ហាញឲ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ដែលចូលរួមបានឃើញ និងប្រាកដថាឈ្មោះគណបក្សដែលបានប្រកាសដូចគ្នានឹងឈ្មោះរបស់គណបក្សដែលបានសរសេរ ឬបោះពុម្ព នៅលើសន្លឹកឆ្នោតនោះមែន ។

៤.២.៣ អគ្គលេខាធិការ គ.ជ.ប ត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោតនេះ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងតំណាងចូលរួម ( គ.ជ.ប តំណាងគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគស្មើគ្នា អ្នកសង្កេតការណ៍.....) ដំណើរការចាប់ឆ្នោត និងលទ្ធផលនៃការចាប់ឆ្នោត ។

៤.២.៤ កំណត់ហេតុ ត្រូវចុះហត្ថលេខាដោយ ៖
- អ្នកធ្វើកំណត់ហេតុ ដែលត្រូវបានចាត់តាំង
- អគ្គលេខាធិការ គ.ជ.ប
- តំណាងគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។

៤.២.៥ កំណត់ហេតុត្រូវធ្វើជា ៤(បួន)ច្បាប់ តាមតម្រូវការដូចខាងក្រោម ៖
- ផ្ញើជូន គ.ជ.ប ១(មួយ) ច្បាប់ ។
- ផ្ញើជូនទៅគ្រប់គណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។
- រក្សាទុកជាឯកសារ ១(មួយ) ច្បាប់ ។

**ប្រការ ៥.-**

ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃក្រោយពីបានទទួលសំណើ ។ បែបបទនៃការទទួលពិនិត្យ និងការអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវ

អនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ មាត្រា២៤ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ និងមាត្រា៣៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងនីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែម ដូចបានកំណត់ខាងក្រោម ។

៥.១ ដើម្បីដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែម គណបក្សនយោបាយដូចមានចែងក្នុងប្រការ ៥ ខាងលើ ត្រូវធ្វើពាក្យសុំតាមបែបបទដែលកំណត់ដោយ គ.ជ.ប ។ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែមជាពីរ (២) ច្បាប់។ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។ ការផ្ទេរសិទ្ធិបន្ត ត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រធានគណបក្ស នយោបាយ។ ពាក្យសុំចុះបញ្ជីនេះ ត្រូវភ្ជាប់ជាមួយនូវ ៖

- ឈ្មោះមណ្ឌលដែលគណបក្សនយោបាយ ត្រូវចុះបញ្ជីបេក្ខជនបន្ថែម និងបញ្ជីបេក្ខជនបន្ថែមឈរឈ្មោះតាមមណ្ឌលទាំងនោះ។
- បញ្ជីបេក្ខជនបន្ថែមឈរឈ្មោះតាមមណ្ឌល ត្រូវមានបេក្ខជនយ៉ាងតិចស្មើនឹងចំនួនអាសនៈនៅក្នុងមណ្ឌលនោះ ។

៥.២ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបន្ថែម ពលរដ្ឋម្នាក់ៗត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត ។
- មានអាយុម្ភៃប្រាំ (២៥) ឆ្នាំឡើងទៅ គិតដល់ថ្ងៃដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែម ។
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។
- មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៥.៣ គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺ ៖

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា ឬ
- ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ
- ជនដែលត្រូវផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត
- ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ
- ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោតដោយ គ.ជ.ប ឬ

- សមាជិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ
- សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

៥.៤ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបេក្ខជនបន្ថែម ប្រសិនបើជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ឬអង្គភាពរបស់ខ្លួនទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីជនត្រូវមានសិទ្ធិឡើងឋានន្តរស័ក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារ សម្រាប់ទទួលសោធននិវត្តន៍ ។ នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមី អង្គភាពជាអ្នកសម្រេច ។

៥.៥ គណបក្សនយោបាយ ដែលបានតែងតាំងបេក្ខជនបន្ថែម ត្រូវបំពេញបែបបទសេចក្តីប្រកាសបេក្ខភាពដែលផ្តល់ដោយ គ.ជ.ប ។ បញ្ជីបេក្ខជនបន្ថែមតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗត្រូវ ៖
- ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។
- មានសេចក្តីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត ។
- ភ្ជាប់សេចក្តីប្រកាសរបស់បេក្ខជន យល់ព្រមទទួលការតែងតាំងជាបេក្ខជនតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗរបស់គណបក្សនយោបាយ ។

៥.៦ គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែមជាបន្ទាន់សមស្រប បន្ទាប់ពីថ្ងៃទទួលបានពាក្យសុំ ។
- ក្នុងករណីយល់ព្រមលើបញ្ជីបេក្ខជនបន្ថែម គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនបន្ថែមជូនគណបក្សនយោបាយ ។
- ប្រសិនបើបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនណាមួយត្រូវបានបដិសេធ ស្របតាមចំណុច ៥.២ ៥.៣ ៥.៤ និងចំណុច ៥.៥ ខាងលើ គ.ជ.ប ត្រូវ ៖
  - បំពេញបែបបទបដិសេធបេក្ខភាព ឬបញ្ជីបេក្ខជនបន្ថែម ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្តីសម្រេចបដិសេធចំនួនបី (៣)ច្បាប់ រួចផ្ញើជូនសាមីខ្លួន និងសាមីគណបក្សនយោបាយមួយ (១)ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញមួយ (១)ច្បាប់ និងរក្សាទុកឯកសារមួយ (១)ច្បាប់ ។

▪ ផ្តល់ព័ត៌មានទៅសាមីខ្លួន ឬសាមីគណបក្សនយោបាយថា គាត់អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរប្រាំ (៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ។

៥.៧ បេក្ខភាពណាដែលត្រូវបានបដិសេធ ឬបញ្ជីបេក្ខជនបន្ថែមរបស់គណបក្សនយោបាយណាដែលត្រូវបានបដិសេធដោយ គ.ជ.ប សាមីខ្លួន ឬសាមីគណបក្សនយោបាយ ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ ។

- ក្នុងករណីទទួលសេចក្តីសម្រេចបដិសេធ និងទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាហើយ ប៉ុន្តែសាមីគណបក្ស ឬតំណាង ពុំបានដាក់ពាក្យប្តឹងតវ៉ាទៅតាមពេលវេលា ដូចចែងក្នុងចំណុច ៥.៧ ទេនោះ ត្រូវចាត់ទុកថាមិនបានប្តឹងតវ៉ា ។
- ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

៥.៨ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមលើពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចយល់ព្រម និងជូនដំណឹងទៅអ្នកប្តឹងតវ៉ា ហើយបង្គាប់ឱ្យ គ.ជ.ប ចុះបញ្ជីបេក្ខជនបន្ថែមជូនសាមីគណបក្សនយោបាយជាបន្ទាន់ ។

- បន្ទាប់ពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាធម្មនុញ្ញ គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីបេក្ខជនបន្ថែម ។
- គ.ជ.ប ត្រូវផ្ញើលិខិតបញ្ជាក់នេះ ១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

៥.៩ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធបណ្តឹងតវ៉ា សេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

- ផ្តល់សេចក្តីសម្រេចបដិសេធនេះ ១ (មួយ) ច្បាប់ ទៅសាមីគណបក្សនយោបាយ ឬតំណាង ។
- ផ្ញើសេចក្តីសម្រេចបដិសេធ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ។

៥.១០ ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាដូចចែងក្នុងប្រការ ៥ នេះ ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។ ករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈដែលនៅទំនេរនេះ តាមបទប្បញ្ញត្តិនៃបទបញ្ជា និងនីតិវិធីនេះ ។

**ប្រការ ៦.-**

ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈ ដែលនៅទំនេររបស់គណបក្សនយោបាយដែលប្រកាសបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈដែលនៅទំនេរនោះ ឱ្យទៅគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា តាមបទប្បញ្ញត្តិដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីនេះ ។

**ប្រការ ៧.-**

បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវទទួលបានរួចហើយ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ តាមលំដាប់លេខរៀងពីបញ្ជីបេក្ខជនដែលនៅជាធរមាន ឬបញ្ជីដែលបានធ្វើបច្ចុប្បន្នភាពរបស់គណបក្សដែលជាប់ឆ្នោត រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដើម្បីពិនិត្យសម្រេច ។